# និន្នាការសេដ្ឋកិច្ចសង្គម

## Socio-Economic Trends

### ប្រចាំខែ កក្កដា ឆ្នាំ ២០១៤ /July, 2014

**មាតិកា** **ទំព័រ**/Page


- អត្ថាធិប្បាយសង្ខេប/Briefing ១
- សូចនាករនាំមុខ/Leading Indicators ៣
- អតិផរណា និងទុនបំរុង/Inflation and Reserve ៤
- អត្រាប្ដូរប្រាក់/Exchange Rates ៥
- រូបិយវត្ថុ និង ធនាគារ/Money and Banking ៦
- ថវិកា /BudgetExecution ៧
- វិនិយោគឯកជន/Private investment ៨
- ពាណិជ្ជកម្ម/Trades ៩


រាជធានីភ្នំពេញថ្ងៃទី ខែ ឆ្នាំ ២០១៤

**ប្រធាននាយកដ្ឋានស្ថិតិ**

## សង្ខេបនិន្នាការសេដ្ឋកិច្ចសង្គម

### សេដ្ឋកិច្ចក្នុងស្រុក

**វិស័យទេសចរណ៍៖** នៅខែ កក្កដា ឆ្នាំ ២០១៤ នេះ ភ្ញៀវទេសចរអន្តរជាតិមកដល់កម្ពុជាសរុបមានចំនួន ៣៨០ ពាន់នាក់ គឺ បានកើនឡើង ១៣,២ ភាគរយ ធៀបនឹងខែមុន ក្នុងនោះភ្ញៀវមកតាមផ្លូវអាកាសច្រកភ្នំពេញ បានកើនឡើង ១២,៣ ភាគរយ តាមផ្លូវអាកាសច្រកសៀមរាបបានកើនឡើង ៣០,២ ភាគរយ និង តាមច្រកផ្លូវគោក និងទឹកបានកើនឡើង ៦ ភាគរយ ។ ក្នុងរយៈពេល៤ខែឆ្នាំនេះ ភ្ញៀវទេសចរអន្តរជាតិសរុបមានចំនួន ២.៥៤១,៤ ពាន់នាក់ ឬ បានកើនឡើង ៤,៥ ភាគរយ ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន បើទោះជាមានភាពរំខានខ្លះៗក្នុងតំបន់ក្តី ។

**វិស័យពាណិជ្ជកម្ម៖** ***ការនាំចូល*** នៅខែ កក្កដា ឆ្នាំ ២០១៤ ការនាំទំនិញចូលសរុបមានតម្លៃជាទឹកប្រាក់ចំនួន ៨៥៦,៥ លានដុល្លារ គឺ បានកើនឡើងប្រមាណ ៤ ភាគរយ ធៀបទៅនឹងខែមុន ក្នុងនោះការនាំចូលបរិក្ខាសំណង់បានកើនឡើង ១៧,៦ ភាគរយ និង ប្រេងឥន្ធនៈបានកើនឡើង ៩,៣ ភាគរយ ក្នុងខណៈដែលការនាំចូលសម្រាប់វាយនភណ្ឌបានថយចុះ ៤,៨ ភាគរយ និងគ្រឿងយន្តបានថយចុះ ១,៤ ភាគរយ ។ សរុបក្នុងរយៈពេល៧ខែដើមឆ្នាំ ២០១៤ មានការកើនឡើង ៦,៦ ភាគរយ ធៀបទៅនឹងរយៈពេលដូចគ្នាក្នុងឆ្នាំកន្លងទៅ ។

***ការនាំចេញ*** នៅខែ កក្កដា ឆ្នាំ ២០១៤ ការនាំចេញទំនិញសរុបមានតម្លៃជាទឹកប្រាក់ចំនួន ៧៣២ លានដុល្លារ គឺបានថកើនឡើង ៤,៦ ភាគរយ ធៀបទៅនឹងខែមុន និង បានកើនឡើង ១៨,៦ ភាគរយ ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ។ ការនាំចេញផលិតផលសំលៀកបំពាក់បានកើនឡើង ៧ ភាគរយ និង ផលិតផលផ្សេងៗទៀតបានក៏មានការកើនឡើងដែរ ។ អង្ករបានថយចុះ ដោយសារកំណើនការផ្គត់ផ្គង់កំហុកលើទីផ្សារអន្តរជាតិជាងការរំពឹងទុក និងកៅស៊ូក៏បានថយចុះផងដែរ ដោយសារការថមថយតម្រូវការទីផ្សារពិភពលោកជាពិសេសទីផ្សារប្រទេសចិន ។ ក្នុងរយៈពេល៧ខែដើមឆ្នាំនេះ ការនាំចេញសរុបទៅកាន់ទីផ្សារអន្តរជាតិមានតំលៃជាទឹកប្រាក់ចំនួន ៤.៥៥១,៦ លានដុល្លារ ។

**សន្ទស្សន៍ថ្លៃទំនិញ៖** សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅក្នុងខែ កក្កដា ឆ្នាំ ២០១៤ បានកើនឡើង ០,៤ ភាគរយ ធៀបនឹងខែកន្លងទៅ និងបានកើនឡើង ៤,២ ភាគរយ បើប្រៀបធៀបទៅនឹង១២ខែមុន ឬ អតិផរណាមធ្យមប្រចាំឆ្នាំ (year average) គិតត្រឹមខែ កក្កដា ឆ្នាំ ២០១៤ មានអត្រា ៤,៤ ភាគរយ ។ **ថ្លៃ**ទំនិញមួយចំនួនដែលមានការកើនឡើង បើធៀបនឹងខែ កក្កដា ឆ្នាំកន្លងទៅ ដូចជា៖ សន្ទស្សន៍ថ្លៃអាហារ និងភេសជ្ជៈមិនមែនជាតិស្រវឹង សន្ទស្សន៍ថ្លៃផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និង ឥន្ធនៈដទៃទៀត សន្ទស្សន៍ថ្លៃគ្រឿងសង្ហារឹមសំភារៈប្រើប្រាស់គ្រួសារ

និងការថែទាំ និង សន្ទស្សន៍ថ្លៃទំនិញនិងសេវាកម្មផ្សេងៗ ក្នុងខណៈដែល សន្ទស្សន៍ថ្លៃគមនាគមន៍ និង សន្ទស្សន៍ថ្លៃភោជនីយដ្ឋានស្ថិតនៅនឹង ។ ចំណែកឯសន្ទស្សន៍ថ្លៃដែលមានការធ្លាក់ចុះមានដូចជា÷ សន្ទស្សន៍ថ្លៃភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ សន្ទស្សន៍ថ្លៃសំលៀកបំពាក់និងស្បែកជើង សន្ទស្សន៍ថ្លៃសេវាសុខាភិបាល សន្ទស្សន៍ថ្លៃការដឹកជញ្ជូន ការកំសាននិងវប្បធម៌ និង សន្ទស្សន៍ការសិក្សា ។

**ការវិនិយោគ÷** គំរោងវិនិយោគឯកជនដែលបានអនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) នៅខែ កក្កដា ឆ្នាំ ២០១៤ មានចំនួន ១៤ គម្រោង គឺ តិចជាងខែកន្លងទៅដែលមានចំនួន ២២ គម្រោង ក្នុងនោះគម្រោងវិនិយោគលើវិស័យកាត់ដេរមានចំនួន ៥ គម្រោង ។ ទុនវិនិយោគសរុប (Fix Asset) មានចំនួន ១១៤,១ លានដុល្លារ គឺ បានកើនឡើង ០,៥ ភាគរយ ធៀបនឹងខែមុន តាមការប៉ាន់ស្មានគម្រោងវិនិយោគនេះ អាចនឹងបង្កើតការងារថ្មីចំនួន ១៧,៣ ពាន់កន្លែង ។ ក្នុងរយៈពេល៧ខែដើមឆ្នាំនេះ ទុនវិនិយោគសរុបបានថយចុះ ៦០,៦ ភាគរយ ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ប៉ុន្តែចំនួនគម្រោងបានកើនឡើង ៣៨,១ ភាគរយ ដោយបង្កើតការងារថ្មីបាន ១១,៩ ភាគរយ ។

**សំណង់÷** គម្រោងស្នើសុំសាងសង់សរុបទូទាំងប្រទេសដែលបានអនុម័តរួចនៅខែ កក្កដា ឆ្នាំ ២០១៤ មានចំនួន ១៦៣ គម្រោង តិចជាងខែមុន ដែលមានចំនួន ១៨៦ គម្រោង ក្នុងនោះគម្រោងអនុម័តដោយក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ បានថយចុះ ៩៤,៤ ភាគរយ និងផ្ទៃក្រឡាបានថយចុះ ៩៧ ភាគរយ ។ គិតជាទឹកប្រាក់លើគម្រោងដែលបានអនុម័តរួចទូទាំងប្រទេស មានចំនួន ៣២,៩ លានដុល្លារ គឺ បានថយចុះ ៨៦ ភាគរយធៀបនឹងខែមុន ។ ចំនួនគម្រោងបានអនុម័តរួចបានកើនឡើង ៤,៥ ភាគរយ ប៉ុន្តែ ផ្ទៃក្រឡាថយចុះ ៦៧,៧ ភាគរយ និងទឹកប្រាក់បានថយចុះ ៦,៨ ភាគរយ ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំកន្លងទៅ ។ រយៈពេល៧ខែដើមឆ្នាំនេះ សរុបផ្ទៃក្រឡាបានកើនឡើង ២៤,១ ភាគរយ និង ទឹកប្រាក់បានកើនឡើង ២៥,៤ ភាគរយ ។

**ថវិកា÷** ***ចំណូល*** នៅខែ កក្កដា ឆ្នាំ ២០១៤ នៅរដ្ឋបាលកណ្តាលចំណូលក្នុងស្រុកអនុវត្តបានចំនួន ៩២០,៤៥ ពាន់លានរៀល គឺបានកើនឡើង ៦១,៩៤ ភាគរយ ធៀបនឹងខែ កក្កដា កាលពីឆ្នាំមុន ។ ចំណូលពីអគ្គនាយកដ្ឋានពន្ធដារបានកើនឡើង ៦៦,៧០ ភាគរយ និង ពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា បានកើនឡើង ៤២,១១ ភាគរយ ។ សរុបនៅក្នុងរយៈពេល៧ខែដើមឆ្នាំ ២០១៤ ចំណូលក្នុងស្រុកអនុវត្តបានចំនួន ៥.៩៧៩,៦១ ពាន់លានរៀល គឺខ្ពស់ជាង ១,៧៩ ភាគរយ នៃគោលដៅប្រមូលក្នុងរយៈពេល៧ខែ និង បានកើនឡើង ២៨,៧៤ ភាគរយបើធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ។

***ចំណាយ*** នៅខែ កក្កដា ឆ្នាំ ២០១៤ ចំណាយសរុបអនុវត្តបានចំនួន ១.០៤៥,៥៨ ពាន់លានរៀល គឺទាបជាង ១៩,១៣ ភាគរយ បើធៀបនឹងខែ កក្កដា កាលពីឆ្នាំមុន គឺ ដោយសារចំណាយមូលធនបានថយចុះ ៥៤,៥៩ ភាគរយ ។ ចំណាយចរន្តអនុវត្តបាន ៧៧៩,៨៧ ពាន់លានរៀល គឺ ខ្ពស់ជាង ១០,២០ ភាគរយ បើធៀបនឹងខែ កក្កដា កាលពីឆ្នាំមុន ក្នុងនោះចំណាយចរន្តសម្រាប់ក្រសួងអាទិភាពអនុវត្តបាន ២៧៥,២០៩ លានរៀល គឺបានកើនឡើង ២២,៥៤ ភាគរយ។ក្នុងរយៈពេល៧ខែដើមឆ្នាំ (គិតត្រឹមខែ កក្កដា) ចំណាយសរុបអនុវត្តបានចំនួន ៥.៦១៨,៨០ ពាន់លានរៀល គឺទាបជាង ១៥,៩៧ ភាគរយ នៃគោលដៅអនុវត្តថវិការយៈពេល៧ខែ ឬ ថយចុះ ១៤,៦៤ ភាគរយ បើធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ ២០១៣ កន្លងទៅ ។

***រូបិយវត្ថុ÷*** ក្នុងរយៈពេល៧ខែដើមឆ្នាំ ២០១៤ រូបិយវត្ថុទូទៅ M2 មានកំណើនជាមធ្យម ២,៧ ភាគរយ ក្នុងមួយខែៗ ដោយឡែកនៅក្នុងខែ កក្កដា ឆ្នាំ ២០១៤ នេះ មានចំនួន ៣៩.៥៩៧ លានរៀល គឺ បានកើនឡើង ៣,៥ ភាគរយ ធៀបនឹងខែកន្លងទៅ និង ៣០,៦ ភាគរយ ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ។ កំណើននេះ គឺបណ្តាលមកពីប្រាក់បញ្ញើមានកាលកំណត់និងសន្សំ (TSD) បានកើនឡើង ៩,៨ ភាគរយ ប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស (FCD) បានកើនឡើង ៣,៤ ភាគរយ និង រូបិយវត្ថុ M1 បានកើនឡើង ២,៤ ភាគរយ ក្នុងនោះ រូបិយវត្ថុក្រៅធនាគារ (COB) កើនឡើង ២,៨ ភាគរយ ក្នុងខណៈដែលប្រាក់បញ្ញើចរន្ត (DD) បានថយចុះ ១,៥ ភាគរយ ទៅវិញ ។ ប្រការនេះ បានធ្វើឱ្យអត្រាប្រាក់រៀល កើនឡើងពី ១៦ ភាគរយ នៅខែ មិថុនា ទៅ ១៧៦, ភាគរយ នៅខែ កក្កដា ធៀបរូបិយវត្ថុទូទៅ M2 ។

## ថ្លៃទំនិញលើទីផ្សារអន្តរជាតិ

**ថ្លៃប្រេងឆៅ÷**នៅខែ សីហា ឆ្នាំ ២០១៤ តម្លៃប្រេងឆៅនៅលើទីផ្សារ អន្តរជាតិ (Oil Brent) សម្រាប់កិច្ចសន្យាលក់មួយខែខាងមុខបានថយចុះ ៤,៧ ភាគរយ ធៀបទៅនឹងខែមុន គឺពី ១០៩,៧ ដុល្លារ/ធុង មក ១០១,៩ ដុល្លារ/ធុង ។ ការប្រែប្រួលតម្លៃប្រេងនៅលើទីផ្សារអន្តរជាតិនេះ ដោយសារការផ្គត់ផ្គង់ប្រេងមានភាពល្អប្រសើរឡើងវិញ គឺ ស្តុកប្រេងរបស់អាមេរិកមានការកើនឡើង ព្រមទាំងមានកំណើនការនាំចេញប្រេងពីប្រទេសលីប៊ីដែលធ្វើឲ្យការផ្គត់ផ្គង់ប្រេងលើទីផ្សារមានការកើនឡើងខ្ពស់ស្របពេលដែលមានការថមថយតម្រូវការប្រើប្រាស់ប្រេងក្នុងលិតកម្មដើម្បីកំណើនសេដ្ឋកិច្ច ជាពិសេសនៅប្រទេសចិន និង សហគមន៍អ៊ឺរ៉ុប ។

**ថ្លៃអង្ករ÷** នៅខែ សីហា ឆ្នាំ ២០១៤ នៅទីក្រុងបាងកកអង្ករនាំចេញ (ខ្ទេច ២៥ ភាគរយ) មានតម្លៃ ៤១៤ ដុល្លារ/តោន គឺ បានកើនឡើង ១០,៤ ភាគរយ ធៀបទៅនឹងខែមុន ដែលមានតម្លៃ ៣៧៥ ដុល្លារ/តោន ។ ថ្លៃអង្ករនាំ

ចេញរបស់ថៃបានកើនឡើង ដោយសារមានកំណើនការប្រើប្រាស់ក្នុងស្រុកនិងតម្រូវការលើទីផ្សារអន្តរជាតិ ស្រប ពេលចំចុងរដូវវស្សាស្តុភាគច្រើនត្រូវបានបញ្ចេញ និង រដូវប្រមូលផលថ្មីមិនទាន់មកដល់ ។

ចំណែកឯនៅប្រទេសវៀតណាមវិញ នៅខែ សីហា ឆ្នាំ ២០១៤ អង្ករនាំចេញ (ខ្ទេច ៥ ភាគរយ) មានតម្លៃ ៤៤២,៦ ដុល្លារ/តោន បានកើនឡើងប្រមាណ ៥,២ ភាគរយ ធៀបទៅនឹងខែមុន គឺពី ៤២០,៩ ដុល្លារ/តោន ។ ការឡើងថ្លៃនេះ គឺបណ្តាលមកពីការផ្គត់ផ្គង់ពីកសិករមានការធ្លាក់ចុះ ដោយមានការរំពឹងទុកអំពីការកើតមានទឹក ទន្លេមេគង្គផង ។

**ថ្លៃកៅស៊ូ÷** នៅខែ សីហា ឆ្នាំ ២០១៤ កៅស៊ូឆៅស្តង់ដារប្រទេសម៉ាឡេស៊ី Standardized Malaysian Rubber (SMR) ប្រភេទ CV នៅទីផ្សារម៉ាឡេស៊ីមានតម្លៃ ២.២៦២ ដុល្លារ/តោន គឺបានថយចុះ ២,៩ ភាគរយ បើប្រៀបធៀបទៅនឹងខែមុន ដែលមានតម្លៃ ២.៣៣០ ដុល្លារ/តោន ។ ប្រការនេះ គឺដោយសារមានការធ្លាក់ចុះតម្រូវការក្នុងឧស្សាហកម្មរបស់ប្រទេសចិន ។

***********

# ៣. ឧបសម្ព័ន្ធ

## សូចនាករនាំមុខ (Leading Indicators)

**Tourist Arrivals ('000 persons)**




Source: Ministry of Tourism

**Total Textile Export (Mn-US$)**




Source: Customs and Excise Dept.

**Import of Gasoline, Steel, Cement ('000T)**




Source: Customs and Excise Dept.

**Construction Approval in P-Penh (m2)**




Source: Min. LMUC

**Rice Prices in Bangkok and Vietnam 2003 = 100**




Source: MEF & Int.

**Crude oil and Gasoline Price, Jan 2003 = 100**




Source: MEF & Int.

# អតិផរណា និង ទុនបំរុងបរទេស (Inflation and Foreign Reserves)




Source: NIS




Source: NIS




Source: NIS




Source: NIS




Source: NBC




Source: NBC

# អត្រាប្តូរប្រាក់ (Exchange Rate)


















# វិស័យរូបិយវត្ថុ និងធនាគារ (Money and Banking)

**Liquidity in Bn-R and in % to GDP**




Source: NBC

**NFA and NDA (Bn-R)**




Source: NBC

**Credit to private sector, CPS (Stock) and growth**




Source: NBC

**Currency outside bank, COB and foreign deposits, FD**




Source: NBC

**Credit to Private Sectors by Sector (Bn-**




Source: NBC

**MFIs and NGOs Loans Outstanding**




Source: NBC

# ការអនុវត្តថវិកា (Budget)


















# វិនិយោគឯកជន និង ការបង្កើតការងារ (Investment and Employment)

**CDC Approval, Fixed Assets and Growth (Mn. $)**




Source: CDC

**CDC Approvals- Fixed Assets by Sectors (Mn. $)**




Source: CDC

**Number of Jobs ('000 person)**




Source: CDC

**Public Investment by Source of Finance (Bn.R)**




Source: MEF

**Net Loans Disbursement (Bn.R)**




Source: MEF

**CDC Approvals, Fixed assets by Sources (Mn. $)**




Source: CDC

# វិស័យពាណិជ្ជកម្ម (Trades)

## Import and Export (mil.US$)




Source: Customs and Excise Department

## Import and Export Growth




Source: Customs and Excise Department

## Export by Commodity Group ( in tonnes)




Souce: Customs and Excise Department, MEF

## Export Clothing and Rubber (mil.US$)




Souce: Customs and Excise Department, MEF

## Export by Main Continents (mil.US$)




Souce: Customs and Excise Department, MEF
(including foreign currency exports )

## Trade Balance and CA as % GDP




Source: National Bank of Cambodia, NBC, and Customs Dept.

# ទិសស័យពាណិជ្ជកម្ម (Trades)

### Export Tax by Group Items (mil. Riels)




Source: Customs and Excise Dept, MEF

### Import Tax by Group Items (mil.Riels)




Source: Customs and Excise Dept, MEF

### Tax Examption (bil.Riels)




Source: Customs and Excise Dept, MEF

### Import by Group Items (mil.Riels)




Source: Customs and Excise Dept, MEF

### Penalty (mil-Riels)
### Total




Source: Customs and Excise Dept, MEF

### Import from Main Continents (mil US$)




Source: Customs and Excise Dep, MEF